ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ប្រកាស
# ស្តីពីការកែសម្រួលប្រការ២ និងប្រការ៣ នៃប្រកាសស្តីពីការគ្រប់គ្រងការដ្ឋានសំណង់

ឆ្នាំ ២០០៩

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

លេខ..៩៣......ប្រក.ដនស/អសណ

# ប្រកាស

## ស្តីពី

## ការកែសម្រួលប្រការ២ និងប្រការ៣ នៃប្រកាសលេខ ៣២ប្រក/សណ

## ស្តីពីការគ្រប់គ្រងការដ្ឋានសំណង់

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីការការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃទីស្តីការគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រម លេខ ០៤/នស/៩៤ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

-បានឃើញអនុក្រឹត្យ លេខ ៦២ អនក្រ.បក ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

-បានឃើញអនុក្រឹត្យ លេខ ៨៦ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីលិខិតអនុញ្ញាតសាងសង់

-យោងប្រកាសលេខ ៣២ ប្រក/សណ ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០០១ ស្តីពីការគ្រប់គ្រងការដ្ឋានសំណង់

-យោងតាមការចាំបាច់របស់ក្រសួង

## <u>សម្រេច</u>

**ប្រការ ១.-**

ត្រូវបានកែសំរួលប្រការ ២ និងប្រការ ៣ នៃប្រកាសលេខ៣២ ប្រក/សណ ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០០១ ស្តីពីការគ្រប់គ្រងការដ្ឋានសំណង់ដូចខាងក្រោម :

<u>ប្រការ២(ថ្មី)</u>: អាចផ្តល់លិខិតអនុញ្ញាតបើកការដ្ឋានសំណង់បានចំពោះតែម្ចាស់សំណង់ណា ដែលមានលិខិតអនុញ្ញាតសាងសង់ ចេញដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឬសាលារាជធានី-ខេត្ត ។

<u>ប្រការ៣(ថ្មី)</u> : ការដ្ឋាននីមួយៗអាចដំណើរការបានលុះត្រាតែមានលិខិតអនុញ្ញាតបើកការដ្ឋាន ។ លិខិតអនុញ្ញាតបើកការដ្ឋាន ត្រូវសុំនៅអគ្គនាយកដ្ឋានសំណង់នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឬមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានី-ខេត្ត បន្ទាប់ពីទទួលបានលិខិតអនុញ្ញាតសាងសង់ស្របតាមសមត្ថកិច្ចចេញលិខិតអនុញ្ញាតសាងសង់ ។ សុំណុំឯកសារដើម្បីសុំលិខិតអនុញ្ញាតបើកការដ្ឋានរួមមាន :

១-សំណុំឯកសារពាក្យសុំរបស់ម្ចាស់សំណង់ ។

២-លិខិតអនុញ្ញាតសាងសង់ ។

៣-ប្លង់ស្ថាបត្យកម្មដែលបានអនុញ្ញាត ។

៤-ប្លង់គ្រឿងផ្គុំសំណង់ ។

**ប្រការ ២.-**

បទប្បញ្ញត្តិណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៣.-**

នាយកខុទ្ទកាល័យ អគ្គនាយកគ្រប់អគ្គនាយកដ្ឋាន គ្រប់ប្រធាននាយកដ្ឋានពាក់ព័ន្ធ និងប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានី-ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ។

ភ្នំពេញ.ថ្ងៃទី.២៦.ខែ.មីនា..ឆ្នាំ.២០០៩

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

អ៊ឹម ឈុនលឹម

<u>កន្លែងទទួល</u>

-ទីស្តីការគណៈរដ្ឋមន្ត្រី
-គ្រប់ក្រសួង ស្ថាប័ន
-គ្រប់សាលារាជធានី-ខេត្ត
-ដូចប្រការ៣
-ឯកសារ-កាលប្បវត្តិ